**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣៤០
ចុះថ្ងៃទី ២៩ ខែវិច្ឆកា ឆ្នាំ ២០០១
**សាលដីកា**
លេខៈ ៥៤
ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម .......... ជាប្រធាន
២-លោក ............. ជាចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក .................

**តំណាងមហាអយ្យការ**
-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា ៩០(ង) ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០០១នៃសំណុំរឿងរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទអ្នកស្រី រច ប្តីឈ្មោះ សណ ជាម្ចាស់បណ្តឹងសាទុក្ខ អាយុ៥១ ឆ្នាំ ជាត់ខ្មែរ មុខរបរ មេផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ ២២ ផ្លូវ ២៤០ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

និងចុងចម្លើយលោក តកងជាម្ចាស់បណ្តឹងសាទុក្ខ អាយុ៣៤ ឆ្នាំជាតិខ្មែរ មុខរបរពាណិជ្ជករ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៩០ផ្លូវព្រះសីហានុ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក ..............ការពារឲ្យចុងចម្លើយ

***កម្មវត្ថុបណ្តឹងៈ*** ប្តឹងទាមទារប្រាក់ឈ្នួលផ្ទះ និងរំលាយកិច្ចសន្យា

តាមបណ្តឹងសាទុក្ខលេខ ២៩៦ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០១ របស់អ្នកស្រី រច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩០(ង) ចុះថ្ងៃទី២៣ ខែសីហាឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

តាមបណ្តឹងសាទុក្ខលេខ ២៩៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់លោក .............ជាមេធាវី និងតំណាងឲ្យឈ្មោះ តកងប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចមិនសម្រេចពីការសុំដាក់គុកបង្ខំលើរូបកាយ និងត្រង់ចំណុចទី៤ដែលសម្រេចឲ្យឈ្មោះ រច ប្រគល់ប្រាក់ឈ្នួលផ្ទះមួយខែ ៥០០ដុល្លា ដោយមូលហេតុសម្រេចខ្វះចំនួន ២ខែ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤០ ចុះថ្ងៃទី២៩ ខែវិច្ឆកា ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៦ របស់ឈ្មោះ រច ថាខ្លួនបានចុះកិច្ចសន្យាជួលផ្ទះចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៦ រយៈពេល ៥ឆ្នាំដោយគិតប្រាក់ឈ្នួលផ្ទះ ២០០០ដុល្លា ក្នុងមួយខែដោយឲ្យបង់ប្រាក់ឈ្នួន ១២ ខែមុន តែឈ្មោះ តាំង កុកង៉ាង បង់តែ ១៤០០០ដុល្លា នៅខ្វះ១០០០០ដុល្លា ទៀត ។ រីឯប្រាក់ឈ្នួលផ្ទះប្រចាំខែត្រូវបង់នៅថ្ងៃទី០៥ ជារៀងរាល់ខែ តែចាប់ពីជួលរហូតដល់ពេលនេះ តកងពុំព្រមបង់ប្រាក់ឈ្នួលផ្ទះទេ ថែមទាំងយកផ្ទះរបស់ខ្លួនជួលទៅឲ្យក្រុមហ៊ុន SDV បន្តទៀត ហើយប្រាក់ឈ្នួលដែលបានឈ្មោះ តកងយកជារបស់គាត់ ។

តាមពាក្យបណ្តឹងតបពុំបានចុះថ្ងៃខែឆ្នាំ២០០០ របស់ឈ្មោះ តកងថាខ្លួនប្តឹងសុំបដិសេធបណ្តឹរបស់អ្នកស្រី រស់ ចន្ទ័ និង សុំឲ្យអ្នកស្រី រស់ ចន្ទ័ អនុវត្តកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៦ រហូតចប់រយៈពេល៥ឆ្នាំ សុំទាមទារប្រាក់កក់ ២៤០០០ដុល្លា មកវិញ ដោយអាងហេតុថា ខ្លួនបានជួលផ្ទះពីអ្នកស្រី រច និងប្តីឈ្មោះ សណ ក្នុងរយៈពេល ៥ឆ្នាំ គិតពីថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៩៦ ដល់ ទី០៥ ខែមេសា ឆ្នាម២០០១ តម្លៃ ២០០០ដុល្លាអាមេរិកក្នុងមួយខែ ដោយបានកក់ប្រកក់មុនមួយឆ្នាំចំនួន ២៤០០០ដុល្លា ឲ្យម្ចាស់ផ្ទះ មានកិច្ចសន្យាជួល ចុះថ្ងៃទី០២ខែមេសា ឆ្នាំ១៩៩៦ ដែលនៅសុពលភាពរហូតដល់សព្វថ្ងៃទី ។ម្យ៉ាងទៀតដោយផ្អែកលើកិច្ចសន្យា ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៦ ខ្លួនបានចុះកិច្ចសន្យាជួលផ្ទះនេះបន្តឲ្យក្រុមហ៊ុន SDV សម្រាប់រយៈពេល៣ឆ្នាំគិតពីថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៦ ដល់ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៩៩ តម្លៃឈ្នួល២៥០០ដុល្លា ក្នុងមួយខែ ។ក្រោយមកអ្នស្រី រចដឹងថាខ្លួនជួលផ្ទះបន្តបានចំណេញ ៥០០ដុល្លាអាមេរិក ក្នុងមួយខែ គាត់ក៏រកលេសប្តឹងតុលាការមកសុំរំលាយកិច្ចសន្យាដោយបំពានថាគាត់ទទួលប្រាក់កក់ និងប្រាក់ថ្ងៃឈ្នួលផ្ទះមិនបានគ្រប់ចំនួនទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២១ (ជ) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៨ ខែតុលាឆ្នាំ១៩៩៦ របស់ឈ្មោះ រច ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-មោឃភាពកិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ១៩៩៦ រវាងឈ្មោះ ស៊ូ ណាល់ និងឈ្មោះ រច ដើមចោទ ជាមួយឈ្មោះ តាំង កុកង៉ាង ចាប់តាំងពីថ្ងៃទីនេះតទៅ ។

៣-បង្គាប់ឲ្យឈ្មោះ តកងចុងចម្លើយ បង់ប្រាក់ឈ្នួលបន្ថែមចំនួន ៤០០០ដុល្លាអាមេរិក ឲ្យទៅឈ្មោះ រច និងប្តីឈ្មោះ ស៊ូ ណាល់ ចាប់ពីថ្ងៃទីសាលក្រមចូលជាស្ថាពរ ។

៤-បង្គាប់ឲ្យឈ្មោះ តកងចុងចម្លើយ សងជម្ងឺចិត្តចំនួន ២០០០ដុល្លាអាមេរិក ឲ្យទៅឈ្មោះ រច និងប្តីឈ្មោះ សណ ចាប់ពីថ្ងៃសាលក្រមស្ថាពរ ។

៥-បង្គាប់ឲ្យឈ្មោះ តកងបង់ប្រាក់ប្រដាប់ក្តីចំនួន ៧០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ចំនួន ៧០០០៛ ដែលដើមចោទបានបង់ទុកជាស្រេច និងបង្គាប់ឲ្យ តកងបង់ពន្ធសមាមាត្រចំនួន ៦០ ដុល្លាអាមេរិក ប្រាក់នេះដាក់ចូលថវិកាជាតិ ចំនួន ៤៨ ដុល្លាអាមេរិក វង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ១២ ដុល្លាអាមេរិក ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះគូក្តីសម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ២ខែ ចាប់ពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៥ (ជ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់លោកមេធាវី សោម ចានឌីណា ទទួលសិទ្ធិពីឈ្មោះ តកងប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២១ (ជ) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣០ (ជ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់អ្នកស្រី រច ប្តឹងមិសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២១ (ជ) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៣ (ខ) ចុះថ្ងៃទី ០៦ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៥ (ជ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់លោក ..............ជាមេធាវីចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣០(ជ) ចុះថ្ងៃទី១៦ខែកក្កដា ឆ្នាំ១៩៩៩ របស់អ្នកស្រីរច ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២១(ជ) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញទុកជាបានការលើកលែងតែចំណុចទី៣ និងទី៤ ត្រូវកែប្រែជាបង្គាប់ឲ្យឈ្មោះ តកងសងប្រាក់ឈ្នួលផ្ទះដែលខ្លួនកាត់យកចំនួន ៥០០០ដុល្លាអាមេរិក និងប្រាក់ឈ្នួលផ្ទះរយៈពេល៥ខែដែលមិនទាន់បានបង់ចំនួន ១០០០០ដុល្លាអាមេរិកព្រមទាំងប្រាក់ថ្លៃជួសជុលផ្ទះចំនួន ៤០០០ដុល្លាអាមេរិក និងបង្គាប់ឲ្យសងជម្ងឺចិត្តចំនួន ៣០០០ដុល្លាអាមេរិក ឲ្យទៅឈ្មោះ រច និងលោក សណ ប៉ុន្តែត្រូកាត់ប្រាក់កក់មុនចំនួន ១៤០០០ដុល្លាអាមេរិក សងទៅឲ្យឈ្មោះ តាំង កុកង៉ាងវិញនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤-រឹបអូសយកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣០០០៛ ដែលឈ្មោះ តកងបានបង់រួចហើយ និងកាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០៛ ដែលឈ្មោះ រច បានបង់រួចហើយ គឺពន្ធចុះបញ្ជី និងពន្ធហ្នឹង ចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ និងអាជ្ញាធរតុលាការ ៥០០០៛

នៅពេលសាលដីកានេះចូលជាស្ថាពរ បង្គាប៉ោឲ្យឈ្មោះ តកងបង់ប្រាក់ប្រដាប់ក្តីសងវិញ និងបង់ពន្ធសមាមាត្រចំនួនមួយភាគរយ លើទឹកប្រាក់ដែលត្រូវសងសរុប។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ រចនិងកំបាំងមុខចុងចម្លើយ និងមេធាវី បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៥៨ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់លោក ..............មេធាវី របស់ តកងប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៣ (ខ) ចុះថ្ងៃទី០៦ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃញសាលដីការដ្ឋប្បវេណីលេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០ របស់មេធាវីចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ២១ (ជ) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់តុលាការក្រុងភ្នំពេញ និងសាលដីកាលេខ ៤៣(ខ) ចុះថ្ងៃទី០៦ ខែកុម្ភៈឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

៣-ទទួលស្គាល់កិច្ចសន្យាចុះថ្ងៃទី០២ ខែមេសាឆ្នាំ១៩៩៦ រវាងឈ្មោះ សួ ណាល់ -រច និងឈ្មោះ តកងទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-បង្គាប់ឲ្យឈ្មោះ តកងប្រគល់ប្រាក់ឈ្នួលផ្ទះក្នុងមួយខែ ១០០០ដុល្លា ដែលនៅជំពាក់ចំនួន ៥ខែ គឺ ៥ គុណ ១០០០ដុល្លា=៥០០០ដុល្លា និងប្រាក់ឈ្នួលដែលមិនទាន់បានបង់ចំនួន ៥ខែគឺ ៥គុណ២០០០ដុល្លា=១០០០០ ដុល្លា ទៅឲ្យឈ្មោះ រចជាដើមចោទ ។

-បង្គាប់ឲ្យឈ្មោះ រច ប្រគល់ប្រាក់កក់ចំនួន ២៤០០០ដុល្លា និងប្រាក់ឈ្នួលផ្ទះក្នុងមួយខែ៥០០ដុល្លាចំនួន ២៤ខែគឺ ២៤ គុណ ៥០០ដុល្លា=១២០០០ដុល្លា ឲ្យទៅឈ្មោះ តកងជាចុងចម្លើយវិញ ។

៥-ក្នុងករណីភាគីណាមួយពុំព្រមសង អនុញ្ញាតិឲ្យរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង ដើម្បីកាត់ប្រាក់ដែលត្រូវសង ។

៦-កាត់យកប្រក់ប្រដាប់ក្តីដាន់សាលាឧទ្ធរចំនួន ១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥០០០៛ ចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០៛ សរុប ១៣០០០៛

-កាលបើសាលដីកានេះចូលជាស្ថាពរ បង្គាប់ឲ្យឈ្មោះ រច បង់ពន្ធសមាមាត្រមួយភាគរយលើទឹកប្រាក់ ៣៦០០០ដុល្លា និងឲ្យឈ្មោះ តាំង កុកង៉ា បង់ពន្ធសមាមាត្រមួយភាគរយលើទឹកប្រាក់ ១៥០០០ដុល្លា ប្រាក់នេះដាក់ចូលថវិការដ្ឋ ៨០ ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៧-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឲ្យតាំង កុកង៉ា កំបាំងមុខរច ។

-បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៦ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០១ របស់អ្នកស្រី រច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩០ ង(ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នំ២០០១ របស់សាលាឧទ្ធរណ៍ត្រងចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់លោក ............ជាមេធាវី និងតំណាងឲ្យឈ្មោះ តកងប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចមិនសម្រេចពីការសុំដាក់គុក បង្ខំលើរូបកាយ និងត្រង់ចំណុចទី៤ ដែលសម្រេចឲ្យឈ្មោះ រច ប្រគល់ប្រាក់ឈ្នួលផ្ទះមួយខែ ៥០០០ដុល្លា ដោយមូលហេតុសម្រេចខ្វះចំនួន២ខែ ។

បានឃើញសារណារចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០២ របស់អ្នកស្រី រច ។

បានឃើញសារណាតប់ និងការពារចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ របស់លោក ............ជាមេធាវីតំណាងឲ្យលោក តកង។

បានឃើញសារណាតបចុះថ្ងៃទី១៤ ខែសីហាឆ្នាំ២០០២ របស់អ្នកស្រី រច ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីកាសាលាឧទ្ធរណ៍លេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែប្រាក់លើសប្រចាំខែចំនួន ៥០០ដុល្លាអាមេរិក គុណ ២ខែ =១០០០ដុល្លាអាមេរិក ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី រច ដើមចោទនិងជាម្ចាស់បណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថាៈ ខ្លួនសូមជម្រាប់ឯកឧត្តមថាៈ កន្លងមកសាលាឧទ្ធរណ៍កាត់សេចក្តីដល់តែ២លើកគឺលើកទី១ ទុក៣ឆ្នាំ រំលោយ២ឆ្នាំ លើកទី២ ទុក៥ឆ្នាំ ។ ការជួលគឺរយៈពេល៥ឆ្នាំ ត្រូវកក់លុយ០១ឆ្នាំសម្រាប់ទូទាត់នៅឆ្នាំទី៥ ហើយក្រោយមកមិនដែលឯកភាពគ្នាទេ ។លោក តាំង កុកង៉ាង ធ្វើលិខិតជំពាក់ប្រាក់តែឯងខ្លួនមិនឯកភាពទេ ។ពេលកាត់នៅតុលាការក្រុងភាគី វ៉ាន់ ស៊ូអៀង មិនទទួលស្គាល់ប្រាក់ ១០០០០ដុល្លាអាមេរិក ។ លោក តកងមិនដែលចូលខ្លួនដោះស្រាយនៅតុលាការទេ នៅពេលតុលាការហៅ គឺគាត់ចាំតែយកប្រាក់ចំណេញ ហើយខ្លួនចេះតែចូលដោះស្រាយក្នុងនាមខ្លួនជាម្ចាស់ផ្ទះ ។ក្នុងឋានៈខ្លួនជាម្ចាស់ផ្ទះគឺត្រូវចុះកុងត្រា សូមក្រុមប្រឹក្សាជំនុំជំរះជួយរកយុត្តិធម៌ឲ្យខ្លួនផង ។រឿងជួលផ្ទះខ្លួនសុំរំលោយកិច្ចសន្យា។ខ្លួនទទួលស្គាល់ក្នុងការជំពាក់លុយខ្លួនឯកភាព តែមិនមានផ្លូវច្បាប់ណាមួយដែលថាខ្លួនជំពាក់លោក វ៉ាន់ ស៊ូអៀង ។ ប្រការ៨ បាននិយាយថាៈ លុយកក់គឺត្រូវកាត់នៅចុងឆ្នាំ តែលោកមេធាវីថាគ្មាន ។បញ្ហាលុយ ១០០០ដុល្លាអាមេរិក ខ្លួនពុំបានឯកភាពទេ ។ក្រុមហ៊ុន SDV ចុះកិច្ចសន្យាជាមួយលោក តកងតែ៣ឆ្នាំទេ ដូច្នេះលោក តកងមិនត្រូវបន្តទៀតទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ............ការពារឲ្យចុងចម្លើយ និងជាដើមបណ្តឹងសាទុក្ខ នៅពេលសវនាការថាៈ នៅក្នុងកិច្ចសន្យាមានសរសេរជាលាយលក្ខអក្សរច្បាស់លាស់ រវាងកូនក្តីខ្លួន និងអ្នកស្រី រច ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៦ គឺ២០០០ដុល្លាអាមេរិក ក្នុង១ខែ មាន១២ប្រការ កូនក្តីខ្លួនកន្លងមកពុំបានបំពានកិច្ចសន្យាដូចដែលសម្តីអ្នកស្រី រច និយាយទេ កូនក្តីខ្លួនបានកក់ប្រាក់ត្រឹមត្រូវឲ្យអ្នកស្រី រច ២៤០០០ដុល្លាអាមេរិក ដោយ ១៤០០០ដុល្លាអាមេរិក អ្នកស្រី រច យកជាសាច់ប្រាក់សុទ្ធ និង ១០០០០ដុល្លាអាមេរិក ទៀតបង្វែឲ្យលោក វ៉ាន់ ស៊ូអៀង ហើយលោក វ៉ាន់ ស៊ូអៀង ឆ្លើយទទួលស្គាល់នៅតុលាការថា លោកបានទទួលប្រាក់កក់ ១០០០០ដុល្លាអាមេរិក

ដែរ ។ កិច្ចសន្យាគឺបើកផ្លូវឲ្យកូនក្តីខ្លួនជួលផ្ទះទៅឲ្យអ្នកទី៣បាន។ ការដែលថាកូនក្តីខ្លួនមិនបានបង់ថ្លៃផ្ទះ៥ខែនោះ គឺដោយសារគាត់ប្តឹងទៅតុលាការហើយទុកឲ្យតុលាការដោះស្រាយនិងយល់ថាប្រាក់កក់កូនក្តីខ្លួននៅលើគាត់លើសលប់ទៅហើយ ។ខ្លួនអាចដកបណ្តឹងសាទុក្ខវិញបានចំពោះប្រាក់ ១០០០ដុល្លាអាមេរិក តែការដាក់គុកបង្ខំរូបកាយសូមនៅដដែល ។សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍និងសុំបន្ថែមដាក់គុកបង្ខំលើរូបកាយ។ប្រាក់៥ខែដែលភាគីខ្លួនបានបង់តែ ១០០០ដុល្លាអាមេរិកនេះ គឺមិនមែនជាការកាត់ប្រាក់នេះយកទៅសងដើមបំណុលទេ និងយោងទៅលើប្រាក់កក់ដ៏លើសលប់ ។ ការមិនយកប្រាក់ទៅតម្កល់គឺធ្វើឡើងតែអ្វីទៅតាមផ្លូវច្បាប់ តាមតុលាការប៉ុន្តែចាប់តាំងពីបានប្តឹងគ្នាមក ភាគីដើមចោទក៏មិនបានទាមទារដែរ ។បញ្ហាប្រាក់កក់គឺកិច្ចសន្យា មិនបាននិយាយនៅចុងឆ្នាំទេ ។បើកិច្ចសន្យាគោរពតាមលក្ខខ័ណ្ឌនោះគឺពុំមានការអ្វីគួរឲ្យស៊ាំញ៉ាំឡើយ តែក្រុមហ៊ុន SDV ទៅវិញប្រាក់កក់នោះភាគីខ្លួនមិនទាន់បានកាត់ពីគាត់ទេ ដូច្នេះគាត់ត្រូវកាត់មកឲ្យភាគីខ្លួនវិញ តាមពិតគាត់ត្រូវសងជម្ងឺចិត្តភាគីខ្លួនទៀត តែភាគីខ្លួនមិនទាមទារទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី រច និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីលោក តកង

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់លោក ............មេធាវីលោក តកងនិងបណ្តឹងសាទុក្ខលេខ ២៩៦ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០១ របស់អ្នកស្រី រច ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាការដែលអ្នកស្រី រច លើកឡើងក្នុងសារណាចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០២ ថា តាមកិច្ចសន្យាអ្នកស្រីត្រូវទទួលប្រាក់កក់ ២៤០០០ដុល្លាអាមេរិក ប៉ុន្តែចុងចម្លើយបានកក់ឲ្យអ្នកស្រីតែ ១៤០០០ដុល្លាអាមេរិកទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមសាលដីការដ្ឋប្បវេណីលេខ ១៩៣ ចុះថ្ងៃទី២៩ ខែវិច្ឆកា ២០០១ របស់តុការកំពូលបានទទួលស្គាល់ថាលោក វ៉ាន់ ស៊ូអៀង បានទទួលការប្រាក់ ១០០០០ដុល្លាអាមេរិក ពីអ្នកស្រី រច ដែលជាប្រាក់កក់ថ្លៃជួលផ្ទះមែន ។

-យល់ឃើញថាការដែសាលាឧទ្ធរណ៍ សម្រេចទទួលស្គាល់កិច្ចសន្យារហូតដល់៥ឆ្នាំ ដោយអាងហេតុថា ចុងចម្លើយពុំមានកំហុសទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះចុងចម្លើយមានកំហុសមិនបានបង់ប្រាក់គ្រប់ចំនួន ៥ខែ មិនបានបង់ឈ្នួលផ្ទះសោះ ៥ខែ តាំងពីក្នុងរយៈពេល ៣ឆ្នាំដំបូងម្ល៉េះ ហើយអ្នកស្រី រច ក៏បានប្តឹងក្នុងរយៈពេល៣ឆ្នាំនោះដែរ ប៉ុន្តែដោយគូភាគីបានអនុវត្តកិច្ចសន្យានេះគ្រាប់៣ឆ្នាមហើយ ហើយដើម្បីឲ្យងាយស្រួលក្នុងការទូទាត់ តុលាការកំពូលគប្បីទទួលស្គាល់កិច្ចសន្យានេះ រយៈពេល៣ឆ្នាំគិតពីថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៦ ដល់ថ្ងៃទី០២ខែមេសា ឆ្នាំ

១៩៩៩ ។ហេតុនេះចាប់ពីថ្ងៃទី០២ ខែមេសាឆ្នាំ១៩៩៩ ដល់ថ្ងៃទី០២ ខែមេសាឆ្នាំ២០០១ តុលាការកំពូលពុំគប្បីទទួលស្គាល់កិច្ចសន្យាទៀតទេ ។

-យល់ឃើញថា សាលាឧទ្ធរណ៍ពុំទាន់បានពិចារណាអំពីប្រាក់ថ្លៃឈ្នួនផ្ទះ ២ខែដែលតាមកិច្ចសន្យាគឺរក្សាទុកោឲ្យចុងចម្លើជួសជុសផ្ទះ ប៉ុន្តែចុងចម្លើយពុំបានជួសជុលទេ ហើយបានយកផ្ទះនេះទៅជួសជុលឲ្យក្រុមហ៊ុន SDV តាំងពីថ្ងៃទី០១ ខែមេសាឆ្នាំ១៩៩៦ ម្លេះ ។

-យល់ឃើញថាក្នុងករណីដែលចុងចម្លើយមានកំហុសនាំឲ្យតុលាការរំលាយកិច្ចសន្យាមុនកាលកំណត់ តុលាការគប្បីពិចារណាអំពីជម្ងឺចិត្តផង ។

-យល់ឃើញថាក្នុងការសម្រេចសេចក្តីសាលាឧទ្ធរណ៍ពុំបានសម្រេចអំពីការដាក់គុកបង្ខំលើរូបកាយ និង សម្រេចអំពីប្រាក់ ៥០០ដុល្លាអាមេរិក នៅក្នុងខែកុម្ភះនិងខែមិនា ឆ្នាំ១៩៩៩ ទេ ។

-យល់ឃើញថា លោក តកងបានទទួលដីកាកោះឲ្យមកចូលរួមនាសវនាការនេះហើយ ប៉ុន្តែលោកពុំបានមកចូលរួមសវនាការនេះទេ មានតែមេធាវីរបស់លោកមកចូលរួមដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុជាចំពោះមុខ ។

-យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ខ្លះខុសខ្លះ ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយប៉ន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ២៧៩ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់លោក ............និងបណ្តឹងសាទុក្ខលេខ ២៩៦ ចុះថ្ងៃទី២៨ខែសីហា ឆ្នាំ២០០១ របស់អ្នកស្រី រច ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៩០ (ង) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការលើកលែងតែៈ

ក-ចំណុចទី៣ ត្រង់ឃ្លាចុងក្រោយបន្ថែមថាៈ "ក្នុងរយៈពេល៣ឆ្នាំ ចាប់ពីថ្ងៃទី០២ ខែមេសាឆ្នាំ១៩៩៦ ដល់ថ្ងៃទី០២ខែមេសាឆ្នាំ ១៩៩៩"។

ខ-ចំណុចទី៤ត្រង់ឃ្លាៈ " និងប្រាក់ឈ្នួលផ្ទះក្នុង០១ខែ ៥០០ដុល្លាអាមេរិក ចំនួន ២៤ខែគឺ២៤គុណ៥០០ ដុល្លា = ១២០០០ដុល្លាអាមេរិក " ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៣៤០ ចុះថ្ងៃទី២៩ ខែវិច្ឆកា ២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញត្រង់ប្រាក់ឈ្នួលផ្ទះ ២៤ ខែគុណ ៥០០ដុល្លាអាមេរិក =១២០០០ដុល្លាអាមេរិក ត្រង់ប្រាក់សម្រាប់ជួសជុលផ្ទះចំនួន ២០០០ដុល្លាអាមេរិក គុណ២ ខែ =៤០០០ដុល្លាអាមេរិក ត្រង់ប្រាក់ ៥០០ដុល្លាអាមេរិក គុណ ២ខែ =១០០០ដុល្លាអាមេរិក និងការដាក់គុកបង្ខំលើរូបកាយដើម្បីទាប្រាក់ព្រមទាំងជម្ងឺចិត្ត ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៣៨០០៛ ដែលគូភាគី បានបង់គឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ នៅសល់ ១៩០០០៛ បង្វិលឲ្យគូភាគីវិញ ម្នាក់ពាក់កណ្តាល ។

បង្គាប់ឲ្យគូភាគីនីមួយៗ បង់ពន្ធសមាមាត្រមួយភាគរយលើចំនួនទឹកប្រាក់ដែលត្រូវប្រគល់ឲ្យភាគីម្ខាងទៀត។

៥-សាលដីការនេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ។